ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Nov-2015, 10:50
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការឆ្លើយតបរបស់ VICTOR KOPPE នៅនឹងសំណើរបស់អង្គជំនុំជម្រះតុលាការកំពូល ឲ្យពន្យល់ពីមូលហេតុដែលអវត្តមាននៅក្នុងសវនាការលើបណ្តឹងសាទុក្ខ**

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រំ ផល្លា

លីវ សុវណ្ណា

Doreen CHEN

Xiaoyang NIE

**<u>ផ្ញើជូន</u>៖**

**សហមេធាវី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**

Marie GUIRAUD

១. ដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”)[1] ខ្ញុំ Victor Koppe ជាសហមេធាវីអន្តរជាតិរបស់លោក នួន ជា សូមដាក់ជូនការឆ្លើយតបដូចតទៅនេះ។

២. នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួនទៅលើសំណើសុំភស្តុតាងបន្ថែម និងបញ្ហាដែលពាក់ព័ន្ធ[2]។

៣. នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ខ្ញុំបានផ្ញើសារអេឡិចត្រូនិចមួយជូនលោក Volker Nerlich ដែលជាមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះ ដែលមានខ្លឹមសារដូចខាងក្រោម៖

> ជូនចំពោះលោក Nerlich
>
> ខ្ញុំសរសេរនេះទៅកាន់លោកក្នុងនាមលោកជាមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះតុលាការកំពូល។
>
> នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ និងបញ្ហាពាក់ព័ន្ធ (“សេចក្តីសម្រេច”)។
>
> នៅក្នុងសេចក្តីសម្រេចអង្គជំនុំជម្រះបានសម្រេច *ក្នុងចំណោមនោះ* ថា ខ្លួននឹងមិនកោះហៅ ហេង សំរិន ក្នុងឋានៈជាសាក្សី និងមិនទទួលយកជាភស្តុតាងនូវប្រតិចារិតភាគច្រើននៃខ្សែភាពយន្តដែលផលិតឡើងដោយផលិតករជនជាតិអង់គ្លេស Robert Lemkin និងអ្នកកាសែតកម្ពុជា ថេត សម្បត្តិ ដោយរាប់បញ្ចូលទាំងកំណត់ត្រា របស់ Robert Lemkin ដែលបានបង្កើតឡើងដោយផ្អែកលើខ្សែភាពយន្តដូចគ្នានេះ។ អង្គជំនុំជម្រះមិនបានបង្ហាញអំពីសម្អាងហេតុសម្រាប់សេចក្តីសម្រេចនេះទេ។
>
> បន្ទាប់ពីសេចក្តីសម្រេចនេះ ជាលទ្ធផលនៃដំណើរការបណ្តឹងសាទុក្ខដែល នួន ជា ដាក់ជូននៅថ្ងៃទី ២៩ កញ្ញា ឆ្នាំ ២០១៤ បានក្លាយជាមិនទាក់ទងសម្រាប់រូបគាត់។ អាស្រ័យហេតុនេះហើយ នួន ជា បានបង្គាប់ដល់យើងខ្ញុំថា គាត់កំពុងតែពិចារណាអំពីជម្រើសសម្រាប់ពេលខាងមុខ ដោយរួមទាំងការដកបណ្តឹងសាទុក្ខរបស់គាត់។

---

[1] ឯកសារ **F30/14** “សេចក្តីសម្រេចបង្គាប់ឱ្យ VICTOR KOPPE ដាក់សារណាទាក់ទងនឹងការខកខានរបស់ខ្លួនក្នុងការចូលរួមក្នុងបណ្តឹងសាទុក្ខ” សូមការពន្យល់ពី ទាក់ទងនឹងការខកខានរបស់ខ្លួន” ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (“សេចក្តីសម្រេចស្នើសុំសារណា”)។

[2] ឯកសារ **F2/9** “សេចក្តីសម្រេចលើសំណើសុំភស្តុតាងបន្ថែមសម្រាប់បណ្តឹងសាទុក្ខ និងបញ្ហាផ្សេងៗ” ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ (“សេចក្តីសម្រេចលើសំណើ”)។

នៅក្នុងវិធានផ្ទៃក្នុងមិនបាននិយាយអំពីលទ្ធភាពនៃការដកបណ្តឹងសាទុក្ខរបស់ជនជាប់ចោទឡើយ។ អាស្រ័យហេតុនេះហើយ ខ្ញុំសរសេរនេះក្នុងនាម នួន ជា ស្នើសុំឱ្យមានការបញ្ជាក់ថា តើតាមផ្លូវច្បាប់ជនជាប់ចោទអាចដកបណ្តឹងសាទុក្ខក្នុងពេលនេះក្នុងដំណើរការនីតិវិធីដែរឬទេ។ ប្រសិនបើអាចសូមលោកជម្រាបបានទេថា នៅពេលណា ហើយក្នុងលក្ខណៈបែបណាដែល នួន ជា អាចជូនដំណឹងដល់អង្គជំនុំជម្រះអំពីការដកនេះ។

ប្រសិនបើតាមច្បាប់ ជនជាប់ចោទមិនអាចដកបណ្តឹងសាទុក្ខបាននៅក្នុងពេលនេះ សូមលោកបញ្ជាក់បានទេថាតើ នួន ជា និង សហមេធាវីអន្តរជាតិរបស់គាត់ត្រូវតែចូលរួមក្នុងសវនាការដែលអង្គជំនុំជម្រះបានគ្រោងនៅថ្ងៃទី១៦ ដល់ ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ដែរឬទេ។ ប្រសិនបើមិនមែនជាកាតព្វកិច្ចដូចនេះ យើងខ្ញុំសូមជូនដំណឹងថា នួន ជា និង/ឬ សហមេធាវីអន្តរជាតិរបស់លោក អាចជ្រើសរើសមិនចូលរួមក្នុងដំណើរការនេះទេ។

ខ្ញុំក៏សូមឆ្លៀតយកឱកាសនេះជម្រាបផងដែរថា ខ្ញុំក្នុងពេលនេះកំពុងពិចារណាអំពីការដកខ្លួនចេញពីមេធាវីការពារក្តីក្នុងបណ្តឹងឧទ្ធរណ៍។ ខ្ញុំមានគម្រោងពិភាក្សាជាមួយប្រធានអង្គភាពគាំពារការការពារក្តីលោក Isaac Endeley ក្នុងពេលឆាប់ៗ អំពីលទ្ធភាពអនុវត្ត និងផ្លូវច្បាប់សម្រាប់ខ្ញុំក្នុងការដកខ្លួន។ ខ្ញុំនឹងជម្រាបជូនលោកអំពីលទ្ធផលនៃការពិភាក្សានេះក្នុងពេលឆាប់ៗ។

៤. នៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៥ លោក Nerlich បានសរសេរសារអេឡិចត្រូនិចដោយចម្លងជូនគ្រប់ភាគីទាំងអស់ថា៖

អរគុណចំពោះសារអេឡិចត្រូនិចរបស់លោកកាលពីរសៀលថ្ងៃម្សិលមិញ ដែលបានស្នើសុំការបញ្ជាក់ថា តើជនជាប់ចោទអាចដកបណ្តឹងសាទុក្ខរបស់ខ្លួនក្នុងដំណាក់កាលនេះឬក៏អត់។

សូមលោកកត់សម្គាល់ថា វាមិនមែនជាតួនាទីរបស់ខ្ញុំទេ ក្នុងការផ្តល់ដំបូន្មានច្បាប់ទៅភាគីនៅក្នុងដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ សកម្មភាពនីតិវិធីណាមួយដែលលោកអាចមានបំណងធ្វើឡើងក្នុងនាមកូនក្តីរបស់លោក អាចធ្វើទៅកាន់អង្គជំនុំជម្រះតុលាការកំពូលតាមរយៈការដាក់ឯកសារជាផ្លូវការ។

ខ្ញុំកត់សម្គាល់ថា មេធាវីការពារក្តីបានស្នើដោយឡែកសុំឱ្យសារអេឡិចត្រូនិចរបស់លោកដាក់ចូលក្នុងសំណុំរឿង។ សូមលោកចាំថា នេះជារឿងមិនអាចទៅរួចទេ ដោយសារតែសារអេឡិចត្រូនិចរបស់លោកមិនមែនជាការដាក់ឯកសារជូនអង្គជំនុំជម្រះតុលាការកំពូលទេ ហើយក៏មិនមែនជាឧបសម្ព័ន្ធដែរ។

៩. នៅសប្តាហ៍ដដែល ដូចដែរបាននិយាយនៅក្នុងសារអេឡិចត្រូនិចថា ខ្ញុំបានពិភាក្សាជាលក្ខណៈបុគ្គលជាមួយប្រធានអង្គភាពគាំពារការការពារក្តី ដែលខ្ញុំបានបញ្ជាក់ថា ខ្ញុំមិនគ្រាន់តែពិចារណាអំពីការដកខ្លួនចេញតែអំពីបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ តែប៉ុណ្ណោះទេ តែក៏ថែមទាំងសម្រាប់សំណុំរឿង ០០២/០២ ផងដែរ ហើយដែលខ្ញុំនឹងប្រាប់គាត់នៅពេលក្រោយឱ្យបានឆាប់តាមតែអាចធ្វើទៅបាន។

៦. នៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១៥ ខ្ញុំបានបញ្ជាក់ជាសាធារណៈជាថ្មីម្តងទៀតអំពីការដកខ្លួនចេញនេះ នៅក្នុងការឆ្លើយតបទៅនឹងសំណួររបស់បណ្តាញសារព័ត៌មានជាតិ ទាក់ទិននឹងរបាយការណ៍មួយ[3] របស់ The Asian International Justice Initiative, East-West Centre[4] ។ នៅក្នុងការផ្តល់អនុសាសន៍ទាំងនេះខ្ញុំបាននិយាយផងដែរថា អវតក គឺជា "ត្តុកល្ខោនកំប្លែងយ៉ាងពិតប្រាកដ"[5]។

៧. នៅក្នុងសវនាការនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ នួន ជា បានលើកឡើងជាថដែលអំពីអ្វីដែលខ្ញុំបានសរសេររួចមកហើយនៅក្នុងសារអេឡិចត្រូនិចរបស់ខ្ញុំកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ថា ដោយសារតែសេចក្តីសម្រេចលើសំណើដែលធ្វើឡើងដោយអង្គជំនុំជម្រះធ្វើឱ្យគាត់អស់ជំនឿលើអង្គជំនុំជម្រះ អាស្រ័យហេតុនេះហើយ គាត់នឹងមិនលើកឡើងដោយផ្ទាល់មាត់ឬក៏ឆ្លើយទៅនឹងសំណួរនានាពីអង្គជំនុំជម្រះ ឬក៏ភាគីឡើយ។

៨. លោក នួន ជា ក៏បានបញ្ជាក់នៅក្នុសវនាការថា គាត់បានណែនាំខ្ញុំមិនឱ្យមានវត្តមាននៅក្នុងសវនាការ។

---

[3] ឯកសារ **F30/11.1.3** David Cohen, Melanie Hyde, Penelope Van Tuyl, Stephanie Fung, *A Well-Reasoned Opinion? Critical Analysis of the First Case against the Alleged Senior Leaders of the Khmer Rouge (Case 002/01)*, East-West Centre, 2015. របាយការណ៍អាចរកបាននៅគេហទំព័រ: http://www.eastwestcenter.org/system/tdf/private/cohen-wellreasoned2015.pdf?file=1&type=node&id=35372

[4] Phnom Penh Post, 'Deep flaws in KRT's Case 002/01: report', 6 Nov 2015, available at: http://www.phnompenhpost.com/national/deep-flaws-krts-case-00201-report;

[5] The Cambodian Daily, 'Tribunal Judgment Slammed in Damning Report', 6 Nov 2015, available at: https://www.cambodiadaily.com/news/tribunal-judgment-slammed-in-damning-report-99529/.

៩. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចដោយស្នើឲ្យខ្ញុំ "ពន្យល់អំពីមូលហេតុ" ក្នុងការ "ខកខានមិនបានចូលរួមក្នុងសវនាការបណ្តឹងសាទុក្ខ"[6]។

១០. នៅខាងលើនេះជាការឆ្លើយតបរបស់ខ្ញុំទៅនឹងអង្គជំនុំជម្រះ។ នៅពេលនេះ ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា ខ្ញុំបានសម្រេចចិត្តមិនលាលែងពីសហមេធាវីអន្តរជាតិរបស់លោក នួន ជា នោះទេ បើទោះជាខ្ញុំមានជំនឿយ៉ាងមុតមាំដែលថា សវនការដ៏ត្រឹមត្រូវយុត្តិធម៌នៅចំពោះមុខ អវតក ទាំងអង្គជំនុំជម្រះសាលាដំបូង និង តុលាការកំពូល គឺមិនអាចទៅរួច និងបើទោះជាខ្ញុំមានជំនឿយ៉ាងមុតមាំថា អវតក តាមពិត និងតែងតែជាតុក្កតាល្ខោនកម្លែង។

**សហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា**

Victor KOPPE

[6] ឯកសារ **F30/14** "សេចក្តីសម្រេចស្នើសុំសារណា" ទំព័រ ៤។